ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សភាព្រហ្មទណ្ឌ
សំណុំរឿងព្រហ្មទណ្ឌ
លេខ: ៧០
ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៩
សាលដីកា
លេខ: ៣៣ "V"
ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០

# សាលដីកា

## នាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២០

ដោយមានសមាសភាពអង្គជំនុំជម្រះដូចខាងក្រោម ៖

១.លោកស្រី [redacted] ប្រធាន

២.លោក [redacted] ចៅក្រម

៣.លោក [redacted] ចៅក្រម

៤.លោក [redacted] ចៅក្រម

៥.លោក ច័ន្ទ រឌ្ឍី ចៅក្រម

### ក្រឡាបញ្ជីសវនាការ

កញ្ញា [redacted]

### តំណាងមហាអយ្យការ

លោក [redacted] ព្រះរាជអាជ្ញា

### ដើម្បីជំនុំជម្រះ

លើបណ្តឹងសាទុក្ខលេខ៣៧ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ [redacted] សត្យា ចំពោះសាលដីកាព្រហ្មទណ្ឌលេខ ៣៧ ក្រV "ទ.ល" ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១៨ របស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ ដែលមាន ៖

- **ជនជាប់ចោទ ៖**

១-ឈ្មោះ [redacted] សត្យា ហៅ ង៉ា ភេទប្រុស អាយុ២៨ឆ្នាំ ជនជាតិខ្មែរ មុខរបរមិនពិតប្រាកដ ទីកន្លែងកំណើតនៅភូមិផ្សារឆ្នាំង សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន ក្រុងភ្នំពេញ ទីលំនៅបច្ចុប្បន្នមុនពេលឃុំខ្លួននៅ [redacted]

Scanned with CamScanner

[redacted]រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted]"រ" ម្តាយឈ្មោះ [redacted]"រ" ជានីតិជន ទោសពីមុនគ្មាន ។

២-ឈ្មោះ [redacted]សុផាត ហៅ ម៉ៅស្ទីច ភេទប្រុស អាយុ៣៣ឆ្នាំ ជនជាតិខ្មែរ មុខរបររត់ម៉ូតូ ទីកន្លែងកំណើត សង្កាត់បឹងកក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ និងទីលំនៅមុនពេលឃុំខ្លួននៅ [redacted]រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted]"រ" ម្តាយឈ្មោះ [redacted]"រ" មានកូន០១នាក់ ជានីតិជនជន ទោសពីមុនគ្មាន ។

ឃុំខ្លួនតាមដីកាបង្គាប់ឲ្យឃុំខ្លួនលេខ១១៦៦ តព្រ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៤ ។

៣-ឈ្មោះ [redacted]សុភ័ក្ត្រ ហៅ ឌី ភេទប្រុស អាយុ៣៥ឆ្នាំ ជនជាតិខ្មែរ មុខរបរជាងផ្សារដែក ទីកន្លែងកំណើតព្រៃខ្មែរ ឃុំរលាប្អៀរ ខេត្តកំពង់ឆ្នាំង ទីលំនៅបច្ចុប្បន្នមុនពេលឃុំខ្លួន [redacted]រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted](ស) ម្តាយឈ្មោះ [redacted](ស) ប្រពន្ធឈ្មោះ [redacted] មានកូន០១នាក់ ជានីតិជន ទោសពីមុន (មាន) ។

ឃុំខ្លួនតាមដីកាបង្គាប់ឲ្យឃុំខ្លួនលេខ១៣១៦ តព្រ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៤ ។

៤-ឈ្មោះ [redacted]វណ្ណៈ ភេទប្រុស អាយុ៣១ឆ្នាំ ជនជាតិខ្មែរ មុខរបរបើកឡានឈ្នួល ទីកន្លែងកំណើត សង្កាត់អូរឬស្សីទី៤ ខណ្ឌ៧មករា រាជធានីភ្នំពេញ ទីលំនៅបច្ចុប្បន្នមុនពេលឃុំខ្លួន [redacted]រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted](រ) ម្តាយឈ្មោះ [redacted]) ប្រពន្ធឈ្មោះ [redacted] មានកូន០២នាក់ ជានីតិជន ទោសពីមុន (មាន) ។

ឃុំខ្លួនតាមដីកាបង្គាប់ឲ្យឃុំខ្លួនលេខ១១៦៦ តព្រ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៤ ។

**-ជាប់ចោទពីបទ៖ អំពើលួចមានស្ថានទម្ងន់ទោសដោយសារមរណភាពនៃជនរងគ្រោះ** ប្រព្រឹត្តនៅចំណុចផ្ទះលេខ ៩៨E0 ផ្លូវលេខ១១៨ ភូមិ៤ សង្កាត់ផ្សាចាស់ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១២ តាមមាត្រា៣៦០ នៃក្រមព្រហ្មទណ្ឌ ។

**-ដើមបណ្តឹងរដ្ឋប្បវេណី ៖** ឈ្មោះ [redacted]សាវី ភេទស្រី អាយុ៥៣ឆ្នាំ មានទីលំនៅផ្ទះលេខ [redacted]រាជធានីភ្នំពេញ ។

**អំពីអង្គហេតុ ៖**

នៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១២ វេលាម៉ោង១៦ និង៣០នាទី ដើមបណ្តឹងឈ្មោះ [redacted]សាវី បានរៀបចំបិទទ្វារតូបលក់មាស ដោយប្រមូលគ្រឿងអង្គដាក់ចូលក្នុងកាបូប ហើយឲ្យទៅក្មួយឈ្មោះ [redacted]នាត ជិះឡានយកទៅផ្ទះមុន នៅពេលឈ្មោះ [redacted]នាត ទៅដល់ផ្ទះបានចុះពីឡានដើរសំដៅទៅជណ្តើរនៅច្រកឡើងហែម ស្របពេលនោះ ជនសង្ស័យឈ្មោះ [redacted] សត្យា ហៅ ង៉ា បានកាន់អាវុធខ្លីម៉ាកកា៥៩ ចូលទៅភ្ជង់ជនរងគ្រោះឈ្មោះ [redacted]នាត គំរាមយកកាបូបដែលដាក់គ្រឿងអលង្កា ភ្លាមនោះជនរងគ្រោះមិនឲ្យក៏មានការប្រតាយប្រតប់គ្នា ហើយជនសង្ស័យបានបាញ់ទៅលើជនរងគ្រោះចំនួន ០៤គ្រាប់ បណ្តាលឲ្យជនរងគ្រោះស្លាប់នៅនឹងកន្លែង ។ ទើបជនសង្ស័យឆក់កាបូបរត់ឡើងជិះម៉ូតូ



Scanned with CamScanner

ដែលមានឈ្មោះ [redacted] សុផាត ហៅ ម៉ៅស្ទីច កំពុងបញ្ឆេះម៉ូតូចាំលើផ្លូវថ្នល់ ព្រមទាំងមានបក្ខពួកចំនួន០២នាក់ទៀត ឈ្មោះ [redacted] វណ្ណៈ និងឈ្មោះ [redacted] សុភ័ក្ត្រ ចាំមើលសកម្មភាពផ្លូវតាមក្រោយ ហើយនាំគ្នាជិះគេចខ្លួនតែម្តង ។

-បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ២៤១ ក្រ១ "ភ" ភ.ព.ព្រ.ទ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៥ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារដូចតទៅ៖

១.ឱ្យឈ្មោះ [redacted] សុផាត ហៅ ម៉ៅ ស្ទីច ភេទប្រុស អាយុ៣៣ឆ្នាំ និងឈ្មោះ [redacted] វណ្ណៈ ភេទប្រុស អាយុ៣១ឆ្នាំ រួចផុតពីបទចោទ អំពើលួចមានស្ថានទម្ងន់ទោសដោយសារមរណភាពនៃជនរងគ្រោះ ប្រព្រឹត្តនៅចំណុចផ្ទះលេខ៩៨E₀ ផ្លូវលេខ១១៨ ភូមិ៤ សង្កាត់ផ្សារចាស់ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១២ តាមមាត្រា៣៦០ នៃក្រមព្រហ្មទណ្ឌ និងមាត្រា៣៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២.ផ្តន្ទាទោស

ក-ឈ្មោះ [redacted] សត្យា ហៅ ង៉ា ភេទប្រុស អាយុ២៨ឆ្នាំ ។

ខ-ឈ្មោះ [redacted] សុភ័ក្ត្រ ហៅ ឌី ភេទប្រុស អាយុ៣៥ឆ្នាំ ។

-ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់ចំនួន១៧ឆ្នាំ (ដប់ប្រាំពីរ)ឆ្នាំ ។

ពីបទ : លួចមានស្ថានទម្ងន់ទោសដោយសារមរណភាពនៃជនរងគ្រោះ នៅចំណុចផ្ទះលេខ៩៨E₀ ផ្លូវលេខ១១៨ ភូមិ៤ សង្កាត់ផ្សារចាស់ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា៣៦០ នៃក្រមព្រហ្មទណ្ឌ ។

៣.បង្គាប់ឱ្យឈ្មោះ [redacted] សត្យា ហៅ ង៉ា ភេទប្រុស អាយុ២៨ឆ្នាំ និងឈ្មោះ [redacted] សុភ័ក្ត្រ ហៅ ឌី ភេទប្រុស អាយុ៣៥ឆ្នាំ រួមគ្នាសងសំណងរដ្ឋប្បវេណីទៅឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សាវី ភេទស្រី អាយុ៥៣ឆ្នាំ សរុបចំនួន ០៦ (ប្រាំមួយម៉ឺន)ដុល្លារអាមេរិក ការទាមទារលើសពីនេះបដិសេធចោល តាមមាត្រា៣៥៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី២០ ខែមេសា ឆ្នាំ២០១៥ និងថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៥ ចំពោះមុខជនជាប់ចោទ កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី និងកាសជាសាធារណៈ នៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៥ ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

-បានឃើញបណ្តឹងឧទ្ធរណ៍លេខ៤៤៦ ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៥ របស់ជនជាប់ចោទឈ្មោះ [redacted] សត្យា ដែលប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ២៤១ ក្រ១ "ភ"ភ.ព.ព្រ.ទ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៥ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច ។

-បានឃើញបណ្តឹងឧទ្ធរណ៍លេខ៤៩៥ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៥ របស់ជនជាប់ចោទឈ្មោះ [redacted] សុភ័ក្ត្រ ដែលប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ២៤១ ក្រ១ "ភ"ភ.ព.ព្រ.ទ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៥ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច ។

-បានឃើញ សាលដីកាព្រហ្មទណ្ឌ៧៣ ក្រV "ទ.ល" ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១៨ របស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖

Scanned with CamScanner

១-ទទួលបណ្តឹងឧទ្ធរណ៍លេខ៤៤៦ ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៥ របស់ជនជាប់ចោទឈ្មោះ [redacted] សត្យា ហៅ ង៉ា ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ខ្លះ។

២-ទទួលពាក្យបណ្តឹងឧទ្ធរណ៍លេខ៤៩៥ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៥ របស់ជនជាប់ចោទឈ្មោះ [redacted] សុភ័ក្រ្ត ហៅ ឌី ទុកជាត្រឹមត្រូវតាមទម្រង់ តែបដិសេធចោលដោយទាស់ នឹងគតិច្បាប់ ។

៣-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ២៤១ ក្រ១ "ភ" ភ.ព.ព្រ.១ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៥ របស់សាលាដំបូងរាជធានីភ្នំពេញ លើកលែងត្រង់ចំណុចទី២ (ក) ត្រង់ការផ្តន្ទាទោសលើឈ្មោះ [redacted] សត្យា ហៅ ង៉ា ដាក់ពន្ធនាគារកំណត់១៧ឆ្នាំ (ដប់ប្រាំពីរឆ្នាំ) ត្រូវកែប្រែមកជាដាក់ពន្ធនាគារកំណត់១៥ឆ្នាំ(ដប់ប្រាំឆ្នាំ)វិញ ចំណុចក្រៅពីនេះ រក្សាទុកជាបានការដដែល ។

៤.បន្តឃុំខ្លួនឈ្មោះ [redacted] សត្យា ហៅ ង៉ា និងឈ្មោះ [redacted] សុភ័ក្រ្ត ហៅ ឌី ដែលមានសាវតាជាតិដូចខាងលើ តាមនីតិវិធី ។

សាលដីការនេះ ជំនុំជម្រះជាសាធារណៈ នៅសាលសវនាការនៃសាលាឧទ្ធរណ៍ នៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៨ និងប្រកាសជាសាធារណៈ នៅថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១៨ ចំពោះមុខ [redacted] សត្យា ហៅ ង៉ា កំបាំងមុខ [redacted] សុភ័ក្រ្ត ហៅ ឌី និងដើមបណ្តឹងរដ្ឋប្បវេណី ។

ទុកសិទ្ធិប្តឹងទាស់ និងប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

-បានឃើញ បណ្តឹងសាទុក្ខលេខ៣៧ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ [redacted] សត្យា ប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ៧៣ ក្រV "ទល" ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១៨ របស់សាលាឧទ្ធរណ៍ ត្រង់សេចក្តីសម្រេចទាំង ។

## នាពេលសវនាការ

-ចៅក្រមបានអានរបាយការណ៍ ។

-តំណាងមហាអយ្យការអមតុលាការកំពូល ធ្វើសេចក្តីសន្និដ្ឋានថា៖

-យល់ឃើញថា ជនជាប់ចោទ [redacted] សត្យា ហៅ ង៉ា និងឈ្មោះ [redacted] សុភ័ក្រ្ត ហៅ ឌី ត្រូវបានតុលាការអង្គសេចក្តីសម្រេចផ្តន្ទាទោសពីបទ អំពើលួចមានស្ថានទម្ងន់ទោស ដោយសារមរណភាពជនរងគ្រោះ តាមបញ្ញត្តិមាត្រា៣៦០ នៃក្រមព្រហ្មទណ្ឌ ។

- យល់ឃើញថា ការលើកយកមាត្រា៣៦០ នៃក្រមព្រហ្មទណ្ឌមកចោទប្រកាន់ និងផ្តន្ទាទោសពុំត្រឹមត្រូវទេ ដោយហេតុថា មាត្រា៣៦០ ចែងថា "អំពើលួចត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១៥(ដប់ប្រាំ)ឆ្នាំ ទៅ៣០(សាមសិប)ឆ្នាំ ប្រសិនបើអំពើនេះប្រព្រឹត្តមុនពេល ក្នុងពេល ឬក្រោយពេលប្រើហិង្សា ដែលបណ្តាលឲ្យជនរងគ្រោះស្លាប់ដោយគ្មានចេតនាសម្លាប់ តាមអង្គហេតុក្រុមជនជាប់ចោទបានបាញ់សម្លាប់ជនរងគ្រោះបណ្តាលឲ្យស្លាប់នៅនឹងកន្លែងកើតហេតុ ពុំមែនស្ថិតក្នុងលក្ខខណ្ឌគ្មានចេតនាសម្លាប់នោះទេ ។ អំពើរបស់ជនជាប់ចោទ គឺមានការត្រៀមទុកមុន ដែលគប្បី យកមាត្រា២០០ នៃ

Scanned with CamScanner

ក្រមព្រហ្មទណ្ឌ មកចោទប្រកាន់ និងផ្តន្ទាទោសទើបត្រឹមត្រូវ ។ តែដោយសារបណ្តឹងសាទុក្ខនេះ ធ្វើឡើង ដោយជនជាប់ចោទ គប្បីក្រុមប្រឹក្សាពិចារណាលើផលប្រយោជន៍របស់អ្នកប្តឹងសាទុក្ខ ។

- យល់ឃើញថា សាលាឧទ្ធរណ៍បានសម្រេចតម្កល់សាលក្រមសាលាដំបូងរាជធានីភ្នំពេញ លើកលែងចំណុច ការដាក់ទណ្ឌកម្ម ត្រូវកែប្រែពី១៧ (ដប់ប្រាំពីរ)ឆ្នាំ មក១៥(ដប់ប្រាំ)ឆ្នាំ វិញដោយផ្អែកលើភស្តុតាង ការចង្អុលបង្ហាញរបស់សាក្សីនៅកន្លែងកើតហេតុ ក្រៅពីនោះពុំមានអ្វីផ្សេងទៀតទេ ដែលចំណុចនេះត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់ នៅពេលសួរដេញដោល ។

តំណាងមហាអយ្យការ ស្នើក្រុមប្រឹក្សាជំនុំជម្រះសម្រេច ៖

-តំណាងមហាអយ្យការ សូមទុកជូនក្រុមប្រឹក្សា ពិចារណា និងសម្រេចតាមច្បាប់ ។

ជនជាប់ចោទឈ្មោះ [redacted] សត្យា ហៅ ង៉ា បានឆ្លើយថា ខ្ញុំមិនសុខចិត្តដោយសារប៉ូលីសប៉ុស្តិ៍ បឹងត្របែកយករូបថត តាំងពីបទល្មើសគ្រឿងញៀនឆ្នាំ២០១១ មកភ្ជាប់ និងជនជាប់ចោទ៣នាក់ទៀត ។ រូបថតដែលដាក់ទោសខ្ញុំ បានមកពីបទល្មើសពីមុន ទេខ្ញុំមិនដែលស្គាល់៣នាក់នោះទេ ។ ពេលខ្ញុំចេញពីពន្ធនាគារ ខ្ញុំទៅរស់នៅកំពង់សោម អស់រយៈពេល៦ខែ បានមកភ្នំពេញវិញ ពេលកើតហេតុខ្ញុំនៅកំពង់សោម មិនបាននៅភ្នំពេញទេ ។ ថ្ងៃកើតហេតុមានតែគ្រួសារខ្ញុំ និងមិត្តស្រីឈ្មោះ [redacted] សុភី ដែលដឹងថាខ្ញុំនៅកំពង់សោម ។ រឿងនេះគេទម្លាក់កំហុសមកលើខ្ញុំ ។

សូមតុលាការមេត្តាជួយរកយុត្តិធម៌ឱ្យខ្ញុំផង។

លោក [redacted] ស៊ីលវិយ៉ា ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សត្យា ធ្វើសេចក្តីសន្និដ្ឋានថា សូមតុលាការកំពូលពិចារណាទៅលើចម្លើយរបស់កូនក្តីខ្ញុំ ទី១ គាត់មិនដែលស្គាល់ជនជាប់ចោទទាំង៣នាក់នោះទេ ទី២ ថ្ងៃកើតហេតុ កូនក្តីខ្ញុំនៅកំពុងសោម ទី៣ បើពិនិត្យលើរបាយការណ៍សំយោគ តាមចម្លើយសាក្សីគឺមិនបានចង្អុលបង្ហាញ ពីលក្ខណៈកូនក្តីខ្ញុំទេ ចំណុចនេះនៅមានវិមតិសង្ស័យ ។

តាមអង្គហេតុ និងអង្គច្បាប់ឃើញថាជាការចោទប្រកាន់កូនក្តីខ្ញុំ កូនក្តីខ្ញុំមិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ ។ សាលដីកាលេខ៧៣ ក្រ V ទ.ល ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១៨ របស់សាលាឧទ្ធរណ៍មិនត្រឹមត្រូវទេ ខ្ញុំបាទបដិសេធសាលដីកាសាលាឧទ្ធរណ៍ និងសុំឱ្យកូនក្តីខ្ញុំ រួចផុតពីបទចោទ ។

-ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីជនជាប់ចោទ

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

យល់ឃើញថា បណ្តឹងសាទុក្ខលេខ៣៧ ចុះថ្ងៃទី ៣១ ខែមករា ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ [redacted] សត្យា ធ្វើឡើងក្នុងកំណត់ច្បាប់តុលាការកំពូលអាចលើករឿងនេះមកជំនុំជម្រះបានតាមមាត្រា៦៤ នៃច្បាប់ស្តីពីការរៀបចំអង្គការ



Scanned with CamScanner

តុលាការ និងមាត្រា៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

យល់ឃើញថា ការដែលសាលាដំបូងរាជធានីភ្នំពេញ ក៏ដូចជាសាលាឧទ្ធរណ៍ដែរ ដែលបានសម្រេចផ្តន្ទាទោស ឈ្មោះ [redacted] សត្យា ពីបទលួចមានស្ថានទម្ងន់ដោយសារមរណភាពនៃជនរងគ្រោះ ដោយផ្អែកលើចម្លើយរបស់សាក្សីមួយរូបឈ្មោះ [redacted] ម៉ានិត ថាឃើញថាបុរសម្នាក់អាយុប្រហែល២៥ឆ្នាំ មាឌស្គម កំពស់ប្រហែល១,៧២ម សម្បុរសស្លេក មុខស្រួច ចិញ្ចើមក្រាស់ ភ្នែកធំ សក់វែងស្គូតញែកកណ្តាល ជាអ្នកអង្គុយក្នុងច្រកខឿងហែមជិតកន្លែងកើតហេតុ ហើយប៉ូលីសបង្ហាញរូបថត [redacted] សត្យា សាក្សីរូបនេះអះអាងថា ជាជនជាប់ចោទឈ្មោះ [redacted] សត្យា ដែលតុលាការអង្គសេចក្តីបានប្រើប្រាស់ជាភស្តុតាង ដាក់បន្ទុកលើឈ្មោះ [redacted] សត្យា នោះ ។ តុលាការកំពូលពិនិត្យឃើញថា :

-ភស្តុតាងលើភិនភាគជនសង្ស័យតែមួយមុខ មិនគ្រប់គ្រាន់ក្នុងការផ្ទៀងផ្ទាត់រកជនល្មើសទេ ។ សាក្សីមិនដែលធ្លាប់ស្គាល់ឈ្មោះ [redacted] សត្យា ទេដូច្នេះការប្រទះភ្នែកឃើញជននេះនៅច្រកខឿងហែម មិនអាចសំគាល់ថាឈ្មោះ [redacted] សត្យា ទេ ។ ឯការដែលនគរបាលបង្ហាញរូបថតឈ្មោះ [redacted] សត្យា ទៅ សាក្សី ហើយ សាក្សី រូបនេះអះអាងថាជាឈ្មោះ [redacted] សត្យា ក៏មិនមានភាពច្បាស់លាស់ល្មមឲ្យជឿទាំងស្រុងតែលើចម្លើយនេះបានទេ ។ តុលាការត្រូវរកភស្តុតាងដទៃទៀតដើម្បីគួបផ្សំគ្នា បើចង់ដាក់បន្ទុកលើឈ្មោះ [redacted] សត្យា ក្នុងបទល្មើសនេះ ។

-ក្នុងសំណុំរឿងក៏ដូចនាសវនាការរបស់តុលាការកំពូលដែរ ឈ្មោះ [redacted] សត្យា បដិសេធថាមិនដែលស្គាល់ជនជាប់ចោទ៣នាក់ផ្សេងទៀតដែលជាចារីក្នុងបទល្មើសនេះទេ ។ ជននេះក៏បានឆ្លើយរៀងរហូតមកថា បន្ទាប់ពីរួចទោសពីពន្ធនាគារចាប់ពីថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១១ ខ្លួនបានទៅរស់នៅកំពង់សោមជាមួយមិត្តស្រីឈ្មោះ [redacted] សុធី ដល់ខែ០៥ ឆ្នាំ២០១២ ទើបវិលមកភ្នំពេញវិញ ។ ចំណុចនេះ គប្បីធ្វើការផ្ទៀងផ្ទាត់ឲ្យហ្មត់ចត់ មុននឹងសន្និដ្ឋានថាមានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ លើជនណាម្នាក់ ។

-នៅក្នុងអង្គហេតុនេះ បើពិនិត្យទៅចៅក្រមស៊ើបសួរបានបញ្ជូនជនសង្ស័យ៤រូបទៅជំនុំជម្រះ ក្នុងនេះមាន២នាក់គឺ [redacted] សុជាត និង [redacted] ណ្ណៈ ដែលកំពុងអនុវត្តទោសពន្ធនាគារក្នុងបទល្មើសផ្សេង ទើបសាលាដំបូងឲ្យជនទាំងពីរនេះរួចពីបទចោទក្នុងអង្គហេតុនេះ ។

តុលាការកំពូលពិនិត្យឃើញថា មានការខ្វះចន្លោះច្រើននៅក្នុងដំណាក់កាលស៊ើបសួរ ដូច្នេះគប្បីសាលាឧទ្ធរណ៍ពិនិត្យពិចារណាជាថ្មី ។

យល់ឃើញថា បណ្តឹងសាទុក្ខរបស់ជនជាប់ចោទ [redacted] សត្យា មានមូលហេតុសមស្រប ដូចការកំណត់នៃមាត្រា៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ៧៣ "ក្រ V ទ ល" ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១៨របស់សាលាឧទ្ធរណ៍ មិនត្រឹមត្រូវទេ ។

## ហេតុដូច្នេះ

## សម្រេច

១.ទទួល បណ្តឹងសាទុក្ខលេខ៣៧ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ [redacted] សត្យា ។

Scanned with CamScanner

២.បដិសេធ សាលដីកាព្រហ្មទណ្ឌលេខ៧៣ “ក្រ V ទ ល” ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១៨ របស់សាលាឧទ្ធរណ៍ ។

៣.បញ្ជូន សំណុំរឿងព្រហ្មទណ្ឌលេខ៧០ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៩ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជម្រះជាថ្មី ។

សាលដីកានេះ ជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី០៣ ខែកុម្ភៈ និងប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០។

Scanned with CamScanner